ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ស្ពឺ**

-សំណុំរឿងរដ្ឋប្បវេណីលេខ: ៤៧
ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២២
-សាលក្រមរដ្ឋប្បវេណីលេខ:១៤៥"ខ"
ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២២

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២។

**ចៅក្រម**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

-ដើមចោទឈ្មោះ [redacted] លន ភេទស្រី អាយុ ៦៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted]។

**អ្នកតំណាងដោយអាណត្តិ**លោកមេធាវី [redacted] លោកមេធាវី [redacted] និងលោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៃក្រុមមេធាវីកម្ពុជរដ្ឋ [redacted]

-សហចុងចម្លើយឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ ៣១ឆ្នាំ. ឈ្មោះ [redacted] ណារីន ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៥ និងឈ្មោះ [redacted] ធីតា ភេទស្រី កើតថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ មានទីលំ [redacted]។

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវអចលនវត្ថុដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 លេខក្បាលដី ៣៧៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឲ្យមកដើមចោទឈ្មោះ [redacted] លន វិញ។

២.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ចាកចេញ និងប្រគល់ដី និងផ្ទះដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 លេខក្បាលដី ៣៧៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣.ទទួលស្គាល់ដើមចោទឈ្មោះ [redacted] លន ជាម្ចាស់កម្មសិទ្ធិលើដីដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ:05051514-0373 លេខក្បាលដី ៣៧៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។



Scanned with CamScanner

៩.បង្គាប់ឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ**

**ខ.១ ការសង្ខេបអំពីរឿងក្តី** ក្នុងរឿងក្តីនេះ ដើមចោទប្តឹងឲ្យសហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ . បង្គាប់ឲ្យសហចុងចម្លើយចាកចេញ និងប្រគល់ដី និងផ្ទះ និងទទួលស្គាល់ដើមចោទឈ្មោះ [redacted] លន ជាម្ចាស់កម្មសិទ្ធិលើដីដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ:05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ទំហំ ២៩០៤ម² មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដោយសារកាលពីអំឡុងឆ្នាំ១៩៨៥ ដើមចោទបានសុំកូនស្រីម្នាក់ឈ្មោះ [redacted] ជឿង ពីបងស្រីបង្កើតឈ្មោះ [redacted] លាវ។ ដើមចោទបានសម្រេចចិត្តចែកដីឲ្យទៅកូនចិញ្ចឹមឈ្មោះ [redacted] ជឿង ចំនួន ៥កន្លែង ដែលមានដីស្រែចំនួន ៤ កន្លែង និងដីលំនៅដ្ឋានចំនួន ១ កន្លែងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ ក្រោយមកនៅឆ្នាំ២០១៤ ពេលដែលឃុំចុះធ្វើប័ណ្ណកម្មសិទ្ធិ ដើមចោទក៏បានឲ្យមន្ត្រីជំនាញធ្វើជាអំណោយនូវដីទាំងនោះឲ្យទៅឈ្មោះ [redacted] ជឿង។ នៅពេលឈ្មោះ [redacted] ជឿង បានស្លាប់សហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ដែលជាប្តី និងកូនរបស់ឈ្មោះ [redacted] ជឿង បានដេញដើមចោទចេញពីផ្ទះ និងចង់បានដីទាំងអស់។

**ខ.២ ចំណុចវិវាទ:**

សហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ. ចាកចេញ និងប្រគល់ដី និងផ្ទះ និងទទួលស្គាល់ដើមចោទឈ្មោះ [redacted] លន ជាម្ចាស់កម្មសិទ្ធិលើដីដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ:05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ទំហំ ២៩០៤ម² មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

**ខ.៣ ការអះអាងរបស់គូភាគី**

**-ការអះអាងរបស់ដើមចោទ៖** កាលពីអំឡុងឆ្នាំ១៩៨៥ ដើមចោទបានសុំឈ្មោះ [redacted] ជឿង ពីបងស្រីបង្កើតឈ្មោះ [redacted] លាវ តាំងពីក្មួយកើតមកម្លេះ ហើយបងស្រីបង្កើតក៏បានយល់ព្រមឲ្យដើមចោទចិញ្ចឹម ដោយសារតែដើមចោទជាក្រមុំចាស់ មិនមានប្តី។ ក្នុងការរស់នៅជាមួយគ្នានោះគឺដើមចោទបានចិញ្ចឹមបីបាច់ថែរក្សាកូនឈ្មោះ [redacted] ជឿង រហូតដល់ពេលកូនពេញរូបរាងក៏បានរៀបការដោយមានសហចុងចម្លើយឈ្មោះ [redacted] រ៉ា ជាប្តី លុះក្រោយមកដើមចោទមានវ័យកាន់តែចាស់ជរា នឹងគិតរស់នៅជាមួយកូនចិញ្ចឹមឈ្មោះ [redacted] ជឿង និងប្តីឈ្មោះ សឿន រ៉ា រហូតដល់ស្លាប់ ក៏បានសម្រេចចិត្តចែកដីឲ្យទៅកូនចិញ្ចឹមឈ្មោះ [redacted] ជឿង ចំនួន ០៥កន្លែង ដែលមានដីស្រែចំនួន ០៤កន្លែង និងដីលំនៅដ្ឋានចំនួន ១កន្លែងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ តាំងពីមិនទាន់ចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិមកម្លេះ លុះក្រោយមកនៅឆ្នាំ២០១៤ ពេលដែលឃុំចុះធ្វើប័ណ្ណកម្មសិទ្ធិ ដើមចោទក៏បានឲ្យមន្ត្រីជំនាញធ្វើជាអំណោយនូវដីទាំងនោះឲ្យទៅឈ្មោះ [redacted] ជឿង។ កន្លងមកការរស់នៅក្នុងផ្ទះតែមួយរវាងដើមចោទ និងឈ្មោះ [redacted] ជឿង មិនដែលមានជម្លោះ ឬទំនាស់អ្វីកើតឡើងឡើយ។ ទើបតែនៅក្នុងអំឡុងឆ្នាំ២០២១ ពេលដែលឈ្មោះ [redacted] ជឿង ស្លាប់ ស្រាប់តែសហចុងចម្លើយឈ្មោះ [redacted] រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា បានធ្វើទង្វើអសីលធម៌មកលើដើមចោទជាញឹកញាប់ ដូចជាផ្តាច់ភ្លើងមិនឲ្យដើមចោទប្រើប្រាស់ រករឿងឈ្លោះមិនស្តីជាមួយដើមចោទ ហើយក៏មិនដែលមើលថែទាំពេលដែលដើមចោទឈឺ និងមិនដែលផ្គត់ផ្គង់ម្ហូបអាហារអ្វីនោះទេ ថែមទាំងធ្វើទង្វើរករឿងបង្កការលំបាកមកឲ្យដើមចោទជាញឹកញាប់ លុះពេលដែលដើមចោទអត់ទ្រាំ នឹងទង្វើរបស់សហចុងម្លើយមិនបាន ក៏សម្រេចចិត្តសុំដីដែលដើមចោទចែកឲ្យទំហំ ៥ម៉ែត្រ គុណ ១០០ម៉ែត្រ ដើម្បីសាងសង់ខ្ទមនៅដាច់ដោយឡែកជាភាពងាយស្រួល កុំឲ្យមានរឿងឈ្លោះប្រកែកគ្នាទៀត ប៉ុន្តែសហចុងចម្លើយមិនព្រមឲ្យ ហើយថែមទាំងប្រើពាក្យសម្តីថា អញមិនឲ្យទេ ចង់ប្តឹងដល់ណាប្តឹងទៅ។

-ការអះអាងរបស់សហចុងចម្លើយ: សហចុងចម្លើយបានរៀបការជាមួយឈ្មោះ [redacted] ជៀង នៅក្នុងឆ្នាំ ២០១០ ក្រោយពេលរៀបការសហចុងចម្លើយបានមករស់នៅខាងប្រពន្ធ ហើយផ្ទះដែលសហចុងចម្លើយរស់នៅនោះមានឪពុកក្មេកឈ្មោះ [redacted] នៃ ម្តាយក្មេកឈ្មោះ [redacted] លាវ ប្រពន្ធឈ្មោះ [redacted] ជៀង និងដើមចោទឈ្មោះ [redacted] លន។ សហចុងចម្លើយមិនដឹងថាផ្ទះខាងប្រពន្ធជាកម្មសិទ្ធិរបស់ដើមចោទ ឬជារបស់ឪពុកម្តាយក្មេកសហចុងចម្លើយទេ អំឡុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធមានកូនពីរនាក់ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា។ ក្រោយមកឪពុកក្មេកបានស្លាប់ប្រហែល ៦ឆ្នាំ ក្រោយមកម្តាយក្មេករបស់សហចុងចម្លើយស្លាប់ នៅឆ្នាំ២០២១ ប្រពន្ធឈ្មោះ [redacted] ជៀង របស់សហចុងចម្លើយក៏ស្លាប់ទៀត ស្រាប់តែដើមចោទទាមទារបែងចែកដីខាងលើ។ ដីដែលដើមចោទទាមទារនេះ ជាដីដែលម្តាយក្មេករបស់សហចុងចម្លើយឈ្មោះ [redacted] លាវ បានចែកឲ្យប្រពន្ធរបស់សហចុងចម្លើយឈ្មោះ [redacted] ជៀង នៅពេលខាងមន្ត្រីជំនាញចុះមកធ្វើប្លង់ជូនប្រជាពលរដ្ឋ។

## សំអាងហេតុ

១.តាមការអះអាងរបស់ដើមចោទ ឃើញថានៅឆ្នាំ១៩៨៥ ដើមចោទបានសុំឈ្មោះ [redacted] ជៀង ពីបងស្រីបង្កើតឈ្មោះ [redacted] លាវ ដើម្បីធ្វើជាកូនចិញ្ចឹម ហើយនៅឆ្នាំ២០១៤ ដើមចោទបានធ្វើអំណោយដីទំហំ ២៩០៤ ម៉ែ ស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឲ្យកូនចិញ្ចឹមឈ្មោះ [redacted] ជៀង នៅពេលដែលឃុំចុះធ្វើប័ណ្ណកម្មសិទ្ធិ ដោយប្រាប់មន្ត្រីជំនាញដាក់ជាអំណោយ និងជាប្រភេទទ្រព្យសម្បត្តិខាងប្រពន្ធ ព្រោះឈ្មោះ [redacted] ជៀង មានប្តីឈ្មោះ [redacted] ភ៉ា និងមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ទំហំ ២៩០៤ម៉ែ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

២.តាមការអះអាងរបស់សហចុងចម្លើយឈ្មោះ [redacted] ភ៉ា ឃើញថាសហចុងចម្លើយបានរៀបការជាមួយឈ្មោះ [redacted] ជៀង នៅក្នុងឆ្នាំ២០១០ ក្រោយពេលរៀបការសហចុងចម្លើយបានមករស់នៅខាងប្រពន្ធដោយមានឪពុកក្មេកឈ្មោះ [redacted] នៃ ម្តាយក្មេកឈ្មោះ [redacted] លាវ ប្រពន្ធឈ្មោះ [redacted] ជៀង និងដើមចោទឈ្មោះ [redacted] លន។ សហចុងចម្លើយមិនដឹងថាផ្ទះខាងប្រពន្ធជាកម្មសិទ្ធិរបស់ដើមចោទ ឬជារបស់ឪពុកម្តាយក្មេកសហចុងចម្លើយទេ។ ពេលរស់នៅជាមួយគ្នាមានកូនឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា។ ក្រោយមកប្រពន្ធឈ្មោះ [redacted] ជៀង បានស្លាប់ ហើយដីទំហំ ២៩០៤ម៉ែ ស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជាដីដែលម្តាយក្មេករបស់សហចុងចម្លើយឈ្មោះ [redacted] លាវ បានចែកឲ្យប្រពន្ធរបស់សហចុងចម្លើយឈ្មោះ [redacted] ជៀង។

ជាការសន្និដ្ឋានការអះអាងរបស់សហចុងចម្លើយថាដីទំហំ ២៩០៤ម៉ែ ស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ជាដីដែលម្តាយក្មេករបស់សហចុងចម្លើយឈ្មោះ [redacted] លាវ បានចែកឲ្យប្រពន្ធរបស់សហចុងចម្លើយឈ្មោះ [redacted] ជៀង ពុំមានភស្តុតាងណាមួយយកមកបញ្ជាក់នោះទេ។

៣.តាមលិខិតបញ្ជាក់ដីធ្លី ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ អាចបញ្ជាក់បានថាវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ទំហំ ២៩០៤ម៉ែ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដើមចោទឈ្មោះ [redacted] លន បានធ្វើប្រទានកម្មទៅឲ្យឈ្មោះ [redacted] ជៀង ពិតប្រាកដមែន។

៤.តាមវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ទំហំ ២៩០៤ម៉ែ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ អាចបញ្ជាក់បានថាគ្រង់ប្រភេទទ្រព្យជាទ្រព្យខាងប្រពន្ធ គ្រង់លេខាចារិកដាក់ថាជាអំណោយ និងកម្មសិទ្ធិរបស់ឈ្មោះ [redacted] ជៀង។

៥.ការទាមទាររបស់ដើមចោទឲ្យសហចុងចម្លើយឈ្មោះ [redacted] ភ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវអចលនវត្ថុដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051 514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម៉ែ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច

ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឃើញថាធ្វើឡើងពុំមានមូលហេតុត្រឹមត្រូវតាមច្បាប់ ហេតុនេះគប្បីតុលាការសម្រេចច្រានចោលការទាមទារនេះ។

៦.គប្បីឲ្យសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដីតាមមាត្រា ៦៤ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**សេចក្ដីសម្រេចបញ្ចប់**

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted]រ៉ា. ឈ្មោះ [redacted] ណារីន និងឈ្មោះ [redacted] ធីតា ចាកចេញ និងប្រគល់ដី និងផ្ទះដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: 05051514-0373 ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឲ្យមកដើមចោទឈ្មោះ [redacted] លន។

២.ទទួលស្គាល់ដើមចោទឈ្មោះ [redacted] លន ជាម្ចាស់កម្មសិទ្ធិលើដីដែលមាននៅក្នុងវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ:05051514-0373 លេខក្បាលដី ៣៧៣ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៤ ដែលមានទំហំ ២៩០៤ម$^2$ មានទីតាំងស្ថិតនៅភូមិព្រៃរោង ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

៣.ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំនុចទី ១ ។

៤.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែគិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅខេត្តកំពង់ស្ពឺ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២២

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner